

# ដំណើររុករករបស់ទីវី និងបូនី

Dewi Tri Kusumah

Dewi Tri Kusumah

Let's Read

The Asia Foundation



ទីវី និងបូនី ជាអ្នករុករកអវកាស។

បេសកកម្មរបស់ពួកគេ គឺស្វែងរកភពមួយ។



ភពនោះ មានរាងមូល និងពណ៌ខៀវ។

ពួកគេត្រូវរកភពនោះឱ្យបានលឿន។

ពួកគេមិនមានពេលច្រើននោះទេ។



ដំបូង ពួកគេត្រូវការយានអវកាសមួយ។ ពួកគេត្រូវស្វែងរក
យានអវកាសនោះនៅក្នុងបន្ទប់ងងឹត។



ទីរី និងបូនី បានរកឃើញយានអវកាសហើយ!

ពួកគេបញ្ឆេះម៉ាស៊ីន។ ពួកគេត្រៀមខ្លួនរួចរាល់សម្រាប់ដំណើររុករកនេះ។ ដំណើរផ្សងព្រេងចាប់ផ្តើម!



យានអវកាសហោះបោះពួយយ៉ាងលឿន



...ទៅកាន់លំហអាកាសដ៏អាថ៌កំបាំង។



វត្ថុជាច្រើនកំពុងរសាត់អណ្ដែតក្នុងលំហអាកាស។
មួយ ពីរ បី នៅមានច្រើនទៀត!



តើក្នុងចំណោមវត្ថុទាំងនោះ មានភពដែលពួកគេកំពុងស្វែងរក
ទេ?



សឺតៗ...សឺតៗ...(សំឡេងហិតក្លិន) ពួកគេឃើញភពពីរដែល
មានរាងមូល
ប៉ុន្តែពួកវាមិនមែនពណ៌ខៀវនោះទេ។



សឺតៗ...សឺតៗ... មានភពពណ៌ត្នោតក្រឡាពងជីងចក់មួយ។ ប៉ុន្តែវាមិនមែនជាភពដែលបូនីកំពុងស្វែងរកនោះទេ។

ទីនោះមានភពរាងមូលមួយទៀតហើយ ប៉ុន្តែវានៅតែមិនមែនជាភពដែលពួកគេកំពុងរកដដែល។



សឺតៗ... សឺតៗ... បូនីធុំក្លិនអ្វីម៉្យាងដូចអ្វីដែលគេធ្លាប់ស្គាល់។



ហ្នឹងហើយ! ភពរបស់ប្ញូនី។



អូ មិនកើតទេ! មានបិសាចដ៏ធំមួយ កំពុងតែឃ្លាមភពនោះ។



បូនីមិនចុះចាញ់ទេ។ បូនីត្រូវតែយកភពនេះឱ្យបាន។ អូយ! បូនីរត់បុកយានអវកាសហើយ។



យានអវកាសរញ្ជួយ វិលខ្វាល់ ហើយក៏ក្រឡាប់!



វូស !





ទេ! យានអវកាសខ្មៅចខ្មីអស់ហើយ។ "ជួយផង!"



«ទីវី?»



ម៉ាក់ទីវី សួរនាងថា៖ «ហេតុអ្វីបានជាកូនមកលេងក្នុងបន្ទប់ក្រោមដី? នៅទីនេះងងឹតណាស់។ ប៉ាកំពុងចាំនៅក្នុងឡាន»។

 ទីវី តបថា៖ «ពួកយើងមករកបាល់របស់បូនី ណាំម៉ាក់។ បូនីមិនព្រមទៅណាទេ បើមិនមានបាល់នោះ»។





"តោះយើងចាប់ផ្ដើមបេសកម្មថ្មីមួយទៀត!"

©2019, The Asia Foundation

គម្រោងបង្កើតសៀវភៅនេះមានក្មេងស្រី និងស្ត្រីដែលមានឥទ្ធិពលជាច្រើនជាតួឯកក្នុងរឿង ចូលរួមដោយអ្នកនិពន្ធ អ្នកគំនូរ អ្នកកែអត្ថបទ និងអ្នករចនាទំព័រសុទ្ធតែជាស្ត្រី។ សៀវភៅនេះត្រូវបានបង្កើតឡើងតាមរយៈកម្មវិធីសិក្ខាសាលាបង្កើតសៀវភៅ ប្រព្រឹត្តទៅក្រោមការសហការរបស់មូលនិធិ លីធារ៉ា និងមូលនិធិអាស៊ីជាមួយការឧបត្ថម្ភពីក្រុមហ៊ុន អេស្ទើ លូតដឺ ។ មូលនិធិលីធារ៉ា ជាអ្នករៀបចំសិក្ខាសាលានិងការអភិវឌ្ឍវិជ្ជាជីវៈ រួមនឹងការកែសម្រួលអត្ថបទ និងការរចនាសៀវភៅ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*Penjelajahan Tiwi dan Boni (The Expeditions of Tiwi and Boni)*, Author: Dewi Tri Kusumah. Illustrator: Dewi Tri Kusumah. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/
Contributing translators: Somey Chheang, Solyda Say, and Prum Kunthearo